**ស្ថានទូតអូស្ត្រាលី**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

## ប្រទេសកម្ពុជា និងប្រទេសអូស្ត្រាលី ពង្រឹងភាពជាដៃគូផ្នែកវិស័យការពារជាតិ

សប្តាហ៍នេះ សកម្មភាពចូលរួមថ្នាក់តំបន់ដ៏សំខាន់របស់ប្រទេសអូស្ត្រាលី ហៅថា ប្រតិបត្តិការកិច្ចខិតខំប្រឹងប្រែងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក Indo-Pacific Endeavor (IPE) បានត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀត ដោយមានកងកម្លាំងជំនាញការពារអូស្ត្រាលី មកជាមួយ ដើម្បីធ្វើការបណ្តុះបណ្តាលជាមួយកងយោធពលខេមរភូមិន្ទ (RCAF)។

ដំណើរទស្សនកិច្ចនេះ ជាផ្នែកមួយនៃការចូលរួមការពារជាតិប្រចាំឆ្នាំ ដើម្បីលើកកម្ពស់សន្តិសុខ និងស្ថិរភាពក្នុងតំបន់។ ក្នុងដំណើរទស្សនកិច្ចនេះ គ្រូបណ្តុះបណ្តាលរបស់កងកម្លាំងការពារអូស្ត្រាលី ចំនួនប្រាំនាក់ បានមកទស្សនាមជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC) របស់កម្ពុជា ដើម្បីផ្តល់ការបណ្តុះបណ្តាលផ្នែករក្សាសន្តិភាព និងយេនឌ័រក្នុងប្រតិបត្តិការយោធា ដល់កងកម្លាំងរបស់កងយោធពលខេមរភូមិន្ទ ខណៈដែលពួកគេរៀបចំសម្រាប់ការដាក់ពង្រាយកងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ដំណើរទស្សនកិច្ចនេះផ្តោតលើការរក្សាសន្តិភាពនិងយេនឌ័រ សន្តិភាព និងសន្តិសុខ រួមទាំងការចូលរួមក្នុងព្រឹត្តិការណ៍បណ្តាញស្ត្រីសម្រាប់កងកម្លាំងយោធាផងដែរ។

Ruth Elsley មេបញ្ជាការកងទ័ពអាកាស របស់ Australian War College បានមានប្រសាសន៍ថា "សកម្មភាព និងការចែករំលែកដែលយើងបានធ្វើជាមួយកងយោធពលខេមរភូមិន្ទ ក្នុងសប្តាហ៍នេះ បានកសាងមិត្តភាព និងការយល់ដឹងរវាងកងកម្លាំងរបស់យើងទាំងពីរ។ កម្ពុជាជាអ្នករួមចំណែកថែរក្សាសន្តិភាពដ៏សំខាន់មួយ។ ឱកាសក្នុងការជួប និងចែករំលែកចំណេះដឹងជាមួយកងកម្លាំងយោធាកម្ពុជា ដែលត្រៀមដាក់ពង្រាយលើប្រតិបត្តិការរក្សាសន្តិភាព ពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន»។

ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា បានមានប្រសាសន៍ថា "ទំនាក់ទំនងវិស័យការពារជាតិរបស់យើងជាមួយប្រទេសកម្ពុជា ដែលមានតាំងពីទសវត្សរ៍ឆ្នាំ១៩៩០មក ពិតជាមានតម្លៃណាស់។ អូស្ត្រាលី និងកម្ពុជាធ្វើការរួមគ្នាលើវិស័យសំខាន់ៗដូចជា កងកម្លាំងរក្សាសន្តិភាព សន្តិសុខដែនសមុទ្រ និងការអភិវឌ្ឍគោលនយោបាយយុទ្ធសាស្ត្រ ក៏ដូចជាការបណ្តុះបណ្តាលភាសាអង់គ្លេស"។

ឯកអគ្គរដ្ឋទូត ចាស្ទីន វ៉ាយអេត បានមានប្រសាសន៍បន្ថែមថា "យើងរីករាយណាស់ដែលវគ្គបណ្តុះបណ្តាលនេះជួយដល់កម្ពុជាសម្រេចគោលដៅ ក្នុងការបង្កើនសមាមាត្រស្ត្រីចូលរួមក្នុងកងកម្លាំងកងយោធពលខេមរភូមិន្ទ ដែលដាក់ពង្រាយលើប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ"។

IPE 2023 បានធ្វើសកម្មភាពលើវិស័យការពារជាតិនេះ ជាមួយប្រទេស បង់ក្លាដែស ប្រ៊ុយណេ កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ស្រីលង្កា ទីម័រខាងកើត ថៃ និងវៀតណាម។

កប៉ាល់របស់កងទ័ពជើងទឹកអូស្ត្រាលី កងទាហានអូស្ត្រាលី និងយន្តហោះរបស់កងទ័ពអាកាសអូស្ត្រាលី ក៏បានជួយដល់សមយុទ្ធនិងសកម្មភាពចូលរួម ចែករំលែកព័ត៌មាន និងឱកាសបណ្តុះបណ្តាលក្នុងកម្មវិធី IPE 2023 ទាំងមូល។

IPE គាំទ្រដល់ការយកចិត្តទុកដាក់របស់រដ្ឋាភិបាលអូស្ត្រាលីលើការពង្រឹងភាពជាដៃគូការទូត និងការពារជាតិនៅទូទាំងអាស៊ីអាគ្នេយ៍ និងមហាសមុទ្រឥណ្ឌាប៉ាស៊ីហ្វិក ព្រមទាំងពង្រឹងការប្តេជ្ញាចិត្តរបស់អូស្ត្រាលីអោយតំបន់មានសន្តិភាព សុវត្ថិភាព និងវិបុលភាព។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au